ABA BANK

NATIONAL BANK OF CANADA GROUP

# សាវតារធនាគារ

ដំណាច់ឆ្នាំ 2023



S&P Global Ratings

# B+

អនាគត៖ ស្ថិរភាព



ABA BANK

NATIONAL BANK OF CANADA GROUP

នៅធនាគារ ABA យើងខ្ញុំកំពុងបន្តបម្រើអតិថិជនជាមួយផលិតផល និងសេវាហិរញ្ញវត្ថុទំនើប ដោយប្រើប្រាស់បច្ចេកវិទ្យាថ្មីៗដែលធ្វើឲ្យអតិថិជនទាំងអស់ទទួលបានសេវាធនាគារលំដាប់ឈានមុខគេ។ យើងខ្ញុំតែងចាត់ទុកអតិថិជនជាអាទិភាពសំខាន់បំផុតនៅក្នុងប្រតិបត្តិការរបស់ខ្លួន ដែលកត្តានេះហើយធ្វើឲ្យយើងខ្ញុំក្លាយជាធនាគារមួយក្នុងចំណោមធនាគារឈានមុខនៅកម្ពុជា។

សូមងាកមកប្រើប្រាស់មធ្យោបាយថ្មីជាមួយធនាគារ ABA ដើម្បីទទួលបានសេវាកម្មពិសេស និងបែបផែនហិរញ្ញវត្ថុដ៏ទំនើបទាន់សម័យ។

ធនាគារ ABA – ដៃគូដែលអ្នកទុកចិត្តបំផុត!

# មាតិកា


- 3 អំពីធនាគារ ABA
- 4 ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ
- 5 រចនាសម្ព័ន្ធអភិបាលកិច្ចសាជីវកម្ម
- 6 ពានរង្វាន់
- 8 របាយការណ៍ហិរញ្ញវត្ថុ
- 9 លទ្ធផលហិរញ្ញវត្ថុ
- 10 ផលិតផល និងសេវាកម្ម
  - *10* *គណនីផ្សេងៗ*
  - *11* *សេវាឥណទាន*
  - *12* *កម្មវិធី ABA Mobile*
  - *13* *កាតទូទាត់*
  - *14* *សេវាផ្ទេរប្រាក់*
  - *15* *ហិរញ្ញប្បទានពាណិជ្ជកម្ម*
  - *16* *បណ្តាញស្វ័យសេវា*
  - *17* *សេវាទំនាក់ទំនងអតិថិជន 24/7*
  - *18* *គណនីរហ័ស*
  - *18* *ABA PayWay*
  - *18* *ABA Business*
- 19 ធនាគារអន្តរការី
- 20 បណ្តាញសាខា

# អំពីធនាគារ ABA




ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (ABA) គឺជាធនាគារមួយក្នុងចំណោមគ្រឹះស្ថានធនាគារកម្រិតខ្ពស់នៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ1996។

ឆ្លងកាត់ការអភិវឌ្ឍ និងកំណើនជាង 25 ឆ្នាំមកនេះ ធនាគារ ABA បានពង្រឹងជំហររបស់ខ្លួននៅលើទីផ្សារយ៉ាងរឹងមាំ និងបានក្លាយជាធនាគារមួយក្នុងចំណោមធនាគារពាណិជ្ជធំៗជាងគេនៅក្នុងប្រទេស។ សព្វថ្ងៃនេះ ABA មានបម្រើសេវាជូនដល់បណ្ដាអតិថិជនជាច្រើនដូចជា សហគ្រាសធុនតូច និងមធ្យម អាជីវកម្មខ្នាតតូច និងរូបវន្តបុគ្គល តាមរយៈបណ្ដាញកំពុងបន្តពង្រីកបាន 92សាខា, ម៉ាស៊ីនស្វ័យសេវា និង ATM ចំនួន1,600, ទីតាំងស្វ័យសេវា 24/7 ចំនួន 45 និងសេវាធនាគារអនឡាញ និងកម្មវិធីសេវាធនាគារតាមទូរស័ព្ទដ៏ទំនើប។

ធនាគារ ABA មានក្រុមជំនាញវិជ្ជាជីវៈ ប្រកបដោយសមត្ថភាព និងស៊ីចង្វាក់គ្នា ដែលមានការប្ដេជ្ញាចិត្តខ្ពស់ក្នុងការរៀបចំ និងលើកកម្ពស់សេវាកម្មរបស់យើង។ គណៈគ្រប់គ្រងអន្តរជាតិយើងខ្ញុំបាននាំមកនូវជំនាញឯកទេសខ្ពស់ដែលអាចធ្វើឲ្យធនាគារ ABA អនុវត្តបានតាមស្តង់ដារសេវាកម្ម និងសុវត្ថិភាពកម្រិតអន្តរជាតិ។

STANDARD &POOR'S

'B+' ចំណាត់ថ្នាក់លទ្ធភាពសងរយៈពេលវែង ពីទីភ្នាក់ងារវាយតម្លៃ Standard & Poor's (S&P) Global Ratings

**អនាគតៈ ស្ថិរភាព**

ធនាគារ ABA ជាបុត្រសម្ព័ន្ធធនាគារជាតិកាណាដាដែលជាគ្រឹះស្ថានហិរញ្ញវត្ថុអាមេរិកខាងជើងទីមួយដែលឈានជើងចូលក្នុងវិស័យធនាគារនៅកម្ពុជា។

ធនាគារ ABA បានទទួលពានរង្វាន់ជ័យលាភីជាធនាគារឆ្នើមបំផុតនៅកម្ពុជាច្រើនឆ្នាំជាប់ៗគ្នា ពីបណ្ដាទស្សនាវដ្ដីហិរញ្ញវត្ថុដ៏ល្បីៗបំផុតរបស់ពិភពលោក រួមមាន The Banker, Euromoney, Global Finance និង Asiamoney។

## ធនាគារអាណាព្យាបាល

NATIONAL BANK OF CANADA

**ធនាគារជាតិកាណាដា** (www.nbc.ca) គឺជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានទ្រព្យសកម្មចំនួន 306 ពាន់លានដុល្លារអាមេរិក គិតត្រឹមថ្ងៃ31 ខែតុលា ឆ្នាំ2023 និងមានបណ្ដាញធនាគារអន្តរការីទូលំទូលាយនៅទូទាំងពិភពលោក។ ធនាគារជាតិកាណាដាទទួលបានចំណាត់ថ្នាក់ឥណទានពីភ្នាក់ងារវាយតម្លៃឥណទានឈានមុខលំដាប់ពិភពលោក ដូចជា ឥណទានកម្រិត "A" ពី S&P, កម្រិត "A+" ពី Fitch, និងកម្រិត "A1" ពី Moody's។

ធនាគារនេះ មានស្នាក់ការកណ្ដាលនៅទីក្រុងម៉ុងរ៉េអាល់ និងមានសាខាស្ទើរគ្រប់ខេត្តនៃប្រទេសកាណាដា ដែលកំពុងបម្រើអតិថិជនចំនួន 2.7លាននាក់។ ធនាគារជាតិកាណាដាគឺជាគ្រឹះស្ថានហិរញ្ញវត្ថុធំជាងគេលំដាប់ទី 6 នៅកាណាដា និងនាំមុខគេនៅកេប៊ិច ជាទីដែលខ្លួនក្លាយជាជម្រើសសម្រាប់បណ្ដាសហគ្រាសធុនតូច និងមធ្យមនានា។

មូលបត្ររបស់ធនាគារ ត្រូវបានចុះបញ្ជីនៅក្នុងក្រុមហ៊ុនមូលបត្រ Toronto Stock Exchange។ អតិថិជននៅសហរដ្ឋអាមេរិក អឺរ៉ុប និងតំបន់ផ្សេងទៀតនៃពិភពលោក ត្រូវបានបម្រើសេវាកម្មជូនតាមរយៈការិយាល័យតំណាង បុត្រសម្ព័ន្ធ និងដៃគូនានា។

# ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

## ចក្ខុវិស័យរបស់យើង

ចក្ខុវិស័យរបស់ធនាគារ គឺដើម្បីក្លាយជាធនាគារលំដាប់លេខមួយប្រចាំប្រទេស លើផ្នែកផ្តត់ផ្តង់សេវាធនាគារគួរជាទីទុកចិត្ត ងាយស្រួលប្រើប្រាស់ ប្រកបដោយបច្ចេកវិទ្យាទំនើបបំផុត និងងាយស្រួលក្នុងការទទួលបាន។ យើងមានបំណងក្លាយជាធនាគារមួយដែលប្រជាជនកម្ពុជាជឿទុកចិត្តក្នុងការបំពេញតម្រូវការសេវាធនាគារផ្ទាល់ខ្លួន និងសម្រាប់អាជីវកម្មរបស់ពួកគាត់ផងដែរ។

## បេសកកម្មរបស់យើង

បេសកកម្មរបស់យើង គឺដើម្បីជួយដល់ប្រទេសកម្ពុជា ធុរកិច្ចកម្ពុជា និងប្រជាជនកម្ពុជានៅក្នុងការកសាងអនាគតកាន់តែទូលំទូលាយ និងត្រចះត្រចង់ តាមរយៈការផ្តល់សេវាធនាគារប្រកបដោយជំនាញវិជ្ជាជីវៈខ្ពស់ និងបច្ចេកវិទ្យាទំនើបបំផុតក្នុងមូលដ្ឋានសេវាធនាគារសម្រាប់ទាំងអស់គ្នា។

យើងចាត់ទុកខ្លួនយើងថាជាដៃគូដ៏ល្អមួយសម្រាប់សហគមន៍កម្ពុជា ក៏ដូចជាអាជីវកម្មឯកជន និងឯកត្តជនផងដែរ។ យើងនៅទីនេះ ដើម្បីផ្តល់សេវាកម្មជូនប្រទេសកម្ពុជា។

## គុណតម្លៃរបស់យើង

### សុចរិតភាព និងសេចក្តីគោរព

នៅធនាគារ ABA យើងចាត់ទុកចំណុចនេះ ជាទំនួលខុសត្រូវរបស់ធនាគារ ដែលត្រូវបម្រើសេវាជូនរាល់អតិថិជនប្រកបដោយសុចរិតភាព និងសេចក្តីគោរព។

### វិភាគទាន

នៅធនាគារ ABA យើងមានបំណងចូលរួមចំណែកវិជ្ជមានសម្រាប់ប្រទេសកម្ពុជា។ យើងចង់ដើរតួនាទីដែលផ្តល់សារប្រយោជន៍សម្រាប់ការរស់នៅរបស់អតិថិជនយើង ក៏ដូចជាសម្រាប់អនាគតរបស់ប្រទេសទាំងមូលផងដែរ។

### ទំនុកចិត្ត និងភាពជាដៃគូ

នៅធនាគារ ABA យើងនៅទីនេះដើម្បីជួយសម្រួល និងជាជំនួយការរបស់លោកអ្នក។ យើងខិតខំធ្វើឲ្យខ្លួនក្លាយជាដៃគូដ៏ល្អដែលអតិថិជនរបស់យើងអាចជឿទុកចិត្តជានិច្ច។

### និរន្តរភាព និងកំណើន

នៅធនាគារ ABA យើងតែងតែគិតគូរអំពីអនាគតរបស់ធនាគារយើង និងប្រជាជនកម្ពុជា ព្រមទាំងប្រទេសកម្ពុជាផងដែរ។ យើងបង្ហាញនូវការប្តេជ្ញាចិត្តដ៏មោះមុតដូចគ្នាចំពោះបុគ្គលិកយើងក៏ដូចជាអតិថិជន។ នេះគឺជាវិធីសាស្រ្តមួយដែលអាចឲ្យយើង ធានាបាននូវភាពរីកចម្រើនប្រកបដោយនិរន្តរភាពរបស់ធនាគារ។

### គុណភាពនៃសេវាកម្ម

នៅធនាគារ ABA យើងខិតខំស្វែងរកដំណោះស្រាយដើម្បីឆ្លើយតបចំពោះរាល់តម្រូវការសេវាធនាគារទាំងអស់។ យើងមានបំណងផ្តល់សេវាកម្មធនាគារប្រកបដោយទំនុកចិត្ត និងមានបច្ចេកវិទ្យាទំនើបបំផុតសម្រាប់អតិថិជនកម្ពុជាទាំងអស់របស់យើង ពោលគឺក្នុងតួនាទីជាជំនួយការគ្រប់គ្រងគណនីផ្ទាល់ខ្លួន ឬគណនីអាជីវកម្មរបស់លោកអ្នក។

### ក្រមសីលធម៌ និងសុជីវធម៌

នៅធនាគារ ABA យើងមានការយកចិត្តទុកដាក់ចំពោះការទទួលខុសត្រូវផ្នែកសង្គមរបស់យើង។ យើងអនុវត្តស្តង់ដារក្រមសីលធម៌ និងសុជីវធម៌ខ្ពស់ រវាងគ្នានឹងគ្នា ព្រមទាំងអ្វីគ្រប់យ៉ាងដែលយើងកំពុងអនុវត្តពោលគឺ ទាំងនៅក្នុង និងក្រៅធនាគារ។ ទាំងនេះគឺជាគោលការណ៍ផ្ទាល់របស់ធនាគារបង្កើតឡើងជាមូលដ្ឋានគ្រឹះសម្រាប់រាល់ទំនាក់ទំនង ពោលគឺជាមួយអតិថិជន និងសហគមន៍ដែលយើងកំពុងផ្តល់សេវាជូន ក៏ដូចជា ជាមួយបុគ្គលិករបស់យើងផងដែរ។

# រចនាសម្ព័ន្ធអភិបាលកិច្ចសាជីវកម្ម

(គិតត្រឹម ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2023)



# ពានរង្វាន់

## 2020

ពានរង្វាន់ “ធនាគារដ៏ឆ្នើមនៅកម្ពុជា” ប្រាំមួយឆ្នាំជាប់គ្នាពីទស្សនាវដ្តី Global Finance ។ ពានរង្វាន់កម្រិតកំពូលនេះប្រគល់ជូនធនាគារ សម្រាប់ការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ចំពោះតម្រូវការរបស់អតិថិជន ហើយសម្រេចបានលទ្ធផលឈានមុខគេ ខណៈដែលខ្លួនកំពុងចាក់គ្រឹះដ៏រឹងមាំសម្រាប់ភាពជោគជ័យនាពេលអនាគត។

ពានរង្វាន់ ធនាគារឆ្នើមនៅកម្ពុជា ប្រាំពីរឆ្នាំជាប់ៗគ្នា ពីទស្សនាវដ្តី Euromoney។ ធនាគារ ABA ត្រូវបានសាទរចំពោះវឌ្ឍនភាពឌីជីថល និងការធ្វើទំនើបកម្មកម្មវិធី ABA Mobile, ការពង្រីកវិសាលភាពបណ្តាញរូបវន្ត និងសមិទ្ធផលសំខាន់ៗផ្សេងទៀត។

ធនាគារ ABA ទទួលបានពានរង្វាន់ "ធនាគារឌីជីថលឆ្នើមនៅកម្ពុជា" រយៈពេលពីរឆ្នាំជាប់គ្នាពីទស្សនាវដ្តី Asiamoney ដែលជាបុត្រសម្ពន្ធរបស់ទស្សនាវដ្តី Euromoney សម្រាប់ឧត្តមភាពនៃផ្លែតហ្វមធនាគារឌីជីថលពិសេសកម្មវិធី ABA Mobile។

## 2021

ពានរង្វាន់ ធនាគារឆ្នើមនៅកម្ពុជា ប្រាំបីឆ្នាំជាប់គ្នា ពីទស្សនាវដ្តី Euromoney។ ABA ត្រូវបានទទួលស្គាល់ពីភាពឈានមុខរបស់ខ្លួនក្នុងដំណោះស្រាយហិរញ្ញវត្ថុឌីជីថល, ការធ្វើទំនើបកម្មកម្មវិធីសេវាធនាគារតាមទូរស័ព្ទដៃ, ការពង្រីកបណ្តាញស្វ័យសេវា 24/7 និងសមិទ្ធផលសំខាន់ៗផ្សេងទៀត។

ធនាគារឆ្នើមប្រចាំឆ្នាំ 2021 នៅកម្ពុជា ប្រសិទ្ធនាមដោយ The Banker។ ពានរង្វាន់នេះ ទទួលស្គាល់យុទ្ធសាស្ត្រផ្តោតលើបច្ចេកវិទ្យានវានុវត្តរបស់ធនាគារ ABA រួមជាមួយផលិតផល និងសេវាឌីជីថល កិច្ចខិតខំប្រឹងប្រែងសំខាន់ៗក្នុងការបង្កើនបរិយាបន្នហិរញ្ញវត្ថុ និងកំណើនដ៏រឹងមាំ។

ពានរង្វាន់ "ធនាគារបម្រើសេវារូបវន្តបុគ្គលដ៏ឆ្នើមប្រចាំឆ្នាំ នៅកម្ពុជា" ដែលផ្តល់ជូន ABA ដោយទស្សនាវដ្តី Asian Banking and Finance ក្នុងកម្មវិធី Retail Banking Awards 2021 សម្រាប់ការបង្កើនសមត្ថភាពផ្លែតហ្វមសេវាធនាគារឌីជីថលជូនអតិថិជន និងការពង្រីកវិសាលភាពនៃបណ្តាញ។

ពានរង្វាន់ ធនាគារឆ្នើមនៅកម្ពុជា ប្រាំពីរឆ្នាំជាប់គ្នា ពីទស្សនាវដ្តី Global Finance។ ពានរង្វាន់នេះ ត្រូវបានប្រគល់ជូន ABA សម្រាប់សមិទ្ធផលនវានុវត្តន៍ ដែលផ្តោតលើអតិថិជនជាចម្បង ខណៈដែលខ្លួនកសាងគ្រឹះសម្រាប់ភាពជោគជ័យនាពេលអនាគត ទោះបីជាមានការរីករាលដាលវីរុសក៏ដោយ។

ពានរង្វាន់ ធនាគារក្នុងស្រុកឆ្នើមបំផុតនៅកម្ពុជា ប្រចាំឆ្នាំ  2021 ពីទស្សនាវដ្តី Asiamoney ជាបុត្រសម្ពន្ធរបស់ទស្សនាវដ្តីហិរញ្ញវត្ថុអន្តរជាតិ Euromoney ត្រូវបានប្រគល់ជូន ABA សម្រាប់ការនាំយកនូវនវានុវត្តហិរញ្ញវត្ថុ និងបង្កើនវិស័យពាណិជ្ជកម្មអេឡិកត្រូនិក អំឡុងពេលនៃការរីករាលដាលជំងឺកូវីដ។

## 2022

ពានរង្វាន់ "ធនាគារឆ្នើមនៅកម្ពុជា" ប្រាំបួនឆ្នាំជាប់គ្នា ពីទស្សនាវដ្តី Euromoney។ ABA ត្រូវបានសាទរចំពោះដំណោះស្រាយសេវាធនាគារប្រកបដោយនវានុវត្តន៍, ការពង្រីកសក្តានុពលយ៉ាងរឹងមាំ, កំណើនគួរឲ្យកត់សម្គាល់ និងការពង្រឹងសមត្ថភាពនៃផ្លែតហ្វមឌីជីថលរបស់ខ្លួន។

ពាន "ធនាគារឆ្នើមនៅកម្ពុជា ប្រចាំឆ្នាំ 2022 " លើកទី 5 ពី The Banker ។ ពាននេះ ទទួលស្គាល់យុទ្ធសាស្ត្រផ្តោតលើបច្ចេកវិទ្យានវានុវត្ត និងសេវាឌីជីថល ការបន្តពង្រឹងកម្មវិធី ABA Mobile និងកំណើនដ៏រឹងមាំរបស់ធនាគារ ABA។

ពាន "ធនាគារបម្រើសេវារូបវន្តបុគ្គលដ៏ឆ្នើមនៅកម្ពុជា ប្រចាំឆ្នាំ 2022" ពី Asian Banking and Finance។ ពាននេះ បានសាទរចំពោះសមិទ្ធផល និងការអភិវឌ្ឍផ្លែតហ្វមឌីជីថលរបស់ធនាគារ ABA ក្នុងការនាំភាពងាយស្រួល និងសេវាធនាគារនវានុវត្តជូនដល់អតិថិជន។

ពាន "ធនាគារឆ្នើមបំផុតនៅកម្ពុជា" ក្នុងរយៈពេល 8 ឆ្នាំជាប់គ្នាពី Global Finance។ ពានកម្រិតឧត្តមភាពមួយនេះ ទទួលស្គាល់ ABA សម្រាប់ការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ចំពោះតម្រូវការអតិថិជនក្នុងទីផ្សារ និងសមិទ្ធផលសម្រេចបានដ៏រឹងមាំរៀងរាល់ឆ្នាំ។

ពាន "ធនាគារដ៏ឆ្នើមបំផុត សម្រាប់ហិរញ្ញវត្ថុឌីជីថលនៅកម្ពុជា ឆ្នាំ2022" ត្រូវបានផ្តល់ជូន ABA សម្រាប់វឌ្ឍនភាពធនាគារឌីជីថល និង យុទ្ធសាស្ត្រផ្តោតលើការបម្រើអតិថិជនជាមួយសេវាធនាគារនវានុវត្ត។

## 2023

ពានរង្វាន់ "ធនាគារឆ្នើមនៅកម្ពុជា" ដប់ឆ្នាំជាប់គ្នា ពីទស្សនាវដ្តី Euromoney។ ABA ត្រូវបានសាទរចំពោះដំណោះស្រាយសេវាធនាគារនវានុវត្ត យុទ្ធសាស្ត្រពង្រីកសក្តានុពលយ៉ាងរឹងមាំ និងកំណើនគួរឲ្យកត់សម្គាល់នៃផ្លែតហ្វមឌីជីថលរបស់ខ្លួន។

ពានរង្វាន់ ធនាគារឆ្នើមប្រចាំឆ្នាំ 2023 របស់ប្រទេសកម្ពុជា ពីទស្សនាវដ្តីហិរញ្ញវត្ថុ The Banker។ ABA ទទួលបានការកោតសរសើរយ៉ាងខ្លាំងចំពោះវឌ្ឍនភាពពេញលេញនៃសេវាធនាគាររបស់ខ្លួន និងយុទ្ធសាស្ត្ររបស់ធនាគារដែលផ្តោតលើបច្ចេកវិទ្យាទំនើប និងផលិតផល/សេវាកម្មឌីជីថល។

ពាន "ធនាគារបម្រើសេវារូបវន្តបុគ្គលដ៏ឆ្នើមនៅកម្ពុជា ប្រចាំឆ្នាំ 2023" ពី Asian Banking and Finance ។ គណៈវិនិច្ឆ័យ បានកត់សម្គាល់ថា កំណើន និងការយកចិត្តទុកដាក់របស់ ABA ចំពោះនវានុវត្តន៍ បានពង្រឹងជំហររបស់ធនាគារ ក្នុងនាមជាគ្រឹះស្ថានឈានមុខ ក្នុងវិស័យធនាគារនៅកម្ពុជា។

ពាន "ធនាគារដ៏ឆ្នើមនៅកម្ពុជា" ប្រាំបួនឆ្នាំជាប់គ្នាពីទស្សនាវដ្តី Global Finance ។ ពានរង្វាន់នេះ សាទរ ABA ចំពោះលទ្ធផលប្រកបដោយភាពជោគជ័យនៅក្នុងទីផ្សារ និងការប្តេជ្ញារបស់ធនាគារ ក្នុងការផ្តល់ជូននូវសេវាធនាគារល្អផ្តាច់ ជូនអតិថិជន។

ធនាគារឌីជីថលឆ្នើមបំផុតនៅកម្ពុជា ឆ្នាំ 2023 ពី International Finance ដែលជាទស្សនាវដ្តីជាន់ខ្ពស់នៅចក្រភពអង់គ្លេស។ ពានរង្វាន់ដ៏មានកិត្យានុភាពនេះ បង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់ ABA ជាបន្តបន្ទាប់ចំពោះនវានុវត្តន៍ មុខងារដ៏ល្អឯកនៃដំណោះស្រាយរបស់ខ្លួន ផ្ទៃអន្តរកម្មងាយស្រួលប្រើ និងទំនាក់ទំនងអតិថិជនដ៏រឹងមាំនៅក្នុងប្រតិបត្តិការធនាគារឌីជីថលរបស់ខ្លួន។

# របាយការណ៍ហិរញ្ញវត្ថុ

| គិតត្រឹមថ្ងៃទី31 ខែធ្នូ | ‘21 ធ្វើសវនកម្ម | ‘22 ធ្វើសវនកម្ម | ‘23 មិនទាន់ធ្វើសវនកម្ម |
|---|---|---|---|
| **តារាងតុល្យការ (គិតជាលានដុល្លារអាមេរិក)** | | | |
| ប្រាក់បញ្ញើសរុប | 6,303.7 | 7,353.6 | 9,232.7 |
| កម្ចីដុលសរុប | 5,325.4 | 6,522.0 | 7,866.4 |
| មូលធនរបស់ម្ចាស់ភាគហ៊ុន | 1,049.8 | 1,312.1 | 1,778.6 |
| ទ្រព្យសកម្មសរុប | 7,861.1 | 9,031.8 | 11,483.2 |
| **គណនីចំណេញ និងខាត (គិតជាលានដុល្លារអាមេរិក)** | | | |
| ចំណូលការប្រាក់សុទ្ធ | 391.7 | 479.3 | 506.5 |
| ចំណូលកម្រៃ និងជើងសាសុទ្ធ និងចំណូលផ្សេងៗ | 39.2 | 49.9 | 53.7 |
| ចំណេញសុទ្ធ | 212.0 | 262.3 | 276.5 |
| **សូចនាករសមិទ្ធកម្មគន្លឹះ (%)** | | | |
| *លទ្ធភាពទទួលបានប្រាក់ចំណេញ* | | | |
| ROAE | 23.8 | 22.2 | 17.8 |
| ROAA | 3.0 | 3.1 | 2.7 |
| ចំណេញការប្រាក់សុទ្ធ | 6.7 | 6.8 | 5.9 |
| ថ្លៃដើម / ចំណូល | 31.7 | 31.0 | 33.9 |
| *មូលនិធិ និងសន្ទនីយភាព* | | | |
| សន្ទនីយភាព | 149.3 | 127.8 | 133.1 |
| អនុបាតឥណទានធៀបបញ្ញើ | 84.5 | 88.9 | 85.6 |
| ទ្រព្យសកម្មសន្ទនីយភាព / ទ្រព្យសកម្មសរុប | 24.3 | 19.5 | 20.1 |
| *មូលធនកម្ម* | | | |
| អនុបាតសាធនភាព | 16.8 | 16.9 | 17.6 |
| ភាគហ៊ុន / ទ្រព្យសកម្មសរុប | 13.4 | 14.5 | 15.5 |
| *គុណភាពទ្រព្យសកម្ម* | | | |
| NPL / ឥណទានសរុប | 0.9 | 2.8 | 3.8 |
| សំវិធានធន / ឥណទានសរុប | 1.6 | 2.8 | 3.8 |

# លទ្ធផលហិរញ្ញវត្ថុ

## ទ្រព្យសកម្ម

**11.5** ពាន់លានដុល្លារអាមេរិក




## ប្រាក់បញ្ញើ

**9.2** ពាន់លានដុល្លារអាមេរិក




## ប្រាក់កម្ចី

**7.9** ពាន់លានដុល្លារអាមេរិក




## ប្រាក់ចំណេញសុទ្ធ

**276.5** លានដុល្លារអាមេរិក




## មូលធនរបស់ម្ចាស់ភាគហ៊ុន

**1.8** ពាន់លានដុល្លារអាមេរិក



# ផលិតផល និងសេវាកម្ម

ធនាគារ ABA ផ្តល់ជូននូវផលិតផលច្រើនសម្បូរបែបដែលបានបង្កើតឡើងដើម្បីជាអត្ថប្រយោជន៍ដល់គ្រប់វិស័យក្នុងសង្គមកម្ពុជា ចាប់ពីប្រាក់កម្ចីអាជីវកម្ម និងហិរញ្ញប្បទានពាណិជ្ជកម្មរហូតដល់កាតទូទាត់ និងប្រាក់បញ្ញើជាដើម។ ផលិតផល និងសេវាកម្មខាងក្រោមនេះត្រូវបានបង្កើតឡើងជាពិសេសដើម្បីបំពេញតាមតម្រូវការសេវាធនាគារប្រចាំថ្ងៃរបស់អតិថិជន។

## គណនីផ្សេងៗ

| | បញ្ញើសន្សំ | បញ្ញើចរន្ត | បញ្ញើចរន្តផ្លឹស | បញ្ញើកាលកំណត់ | បញ្ញើបត់បែន |
|---|---|---|---|---|---|
| បំណង | ប្រតិបត្តិការ និងសន្សំ | ប្រតិបត្តិការ | ប្រតិបត្តិការ | សន្សំ | សន្សំ |
| រូបិយប័ណ្ណ | រៀល<br>ដុល្លារអាមេរិក | រៀល<br>ដុល្លារអាមេរិក | រៀល<br>ដុល្លារអាមេរិក | រៀល<br>ដុល្លារអាមេរិក | រៀល |
| កាតឥណទានឥតគិតថ្លៃ* (Visa, Mastercard) | ✓ | ✓ | ✓ | ✓ | គ្មាន |
| ទឹកប្រាក់តម្កល់ដំបូងអប្បបរមា | គ្មាន | 400,000 រៀល<br>100 ដុល្លារ | 2,000,000 រៀល<br>500 ដុល្លារ | 400,000 រៀល<br>100 ដុល្លារ | 1,000,000 រៀល |
| ទឹកប្រាក់បន្តអប្បបរមា | គ្មាន | 400,000 រៀល<br>100 ដុល្លារ | 2,000,000 រៀល<br>500 ដុល្លារ | គ្មាន | 1,000,000 រៀល |
| អត្រាការប្រាក់ (ក្នុងមួយឆ្នាំ) | រហូតដល់ 1.50% (រៀល)<br>រហូតដល់ 0.70% (ដុល្លារ) | គ្មាន | រហូតដល់ 1.50% (រៀល)<br>រហូតដល់ 0.70% (ដុល្លារ) | រហូតដល់ 6.00% (រៀល)<br>រហូតដល់ 4.50% (ដុល្លារ) | 1.75% (រៀល) |
| ការទូទាត់ការប្រាក់ | រៀងរាល់ខែ ឬពេលបិទគណនី | គ្មាន | រៀងរាល់ខែ ឬពេលបិទគណនី | ប្រចាំខែ ឬចុងគ្រា ឬពេលបិទគណនី | រៀងរាល់ខែ ឬពេលបិទគណនី |

* *លក្ខខណ្ឌនានាត្រូវអនុវត្ត*

ឥណទានអាជីវកម្មរបស់ធនាគារ ABA អនុញ្ញាតឲ្យលោកអ្នកប្រែក្លាយផែនការអាជីវកម្មក្នុងក្តីស្រមៃទៅជាការពិត—មិនថាជាផែនការពង្រីកប្រតិបត្តិការបច្ចុប្បន្ន ឬផែនការបង់ផ្តាច់កម្ចីពីគ្រឹះស្ថានផ្សេងៗ សូមរីករាយជាមួយលក្ខខណ្ឌទទួលបានកម្ចីងាយស្រួល ដែលអាចចរចាបាន ដើម្បីបង្កើនអាជីវកម្មរបស់លោកអ្នក!

បន្ថែមលើកម្ចីអាជីវកម្មនេះ ធនាគារ ABA ផ្តល់កញ្ចប់កម្ចីរូបវន្តបុគ្គលផ្សេងៗជាច្រើនដែលមានភាពបត់បែន និងប្រកួតប្រជែងដែលសក្តិសមនឹងបែបផែនជីវិតរបស់លោកអ្នក។

# សេវាកម្ចី

## សេវាផ្តាច់កម្ចីអាជីវកម្ម

លោកអ្នកដែលមានបំណងចង់សម្រាលបន្ទុកក្នុងការសងកម្ចីប្រចាំខែ ដោយសារលោកអ្នកមានចំណាយបន្ថែម ឬត្រូវការថវិកាដើម្បីពង្រីកអាជីវកម្មនាថ្ងៃអនាគត អាចទទួលយកអត្ថប្រយោជន៍នៃការផ្លាស់ប្តូរកម្ចីដែលមានស្រាប់ពីគ្រឹះស្ថានបច្ចុប្បន្ន មកធនាគារ ABA បាន! យើងខ្ញុំ អាចផ្តល់ការប្រាក់ទាបជាង ជាមួយលក្ខខណ្ឌងាយស្រួលជាង ការបង់សងបត់បែនច្រើនជម្រើស និងអត្ថប្រយោជន៍ផ្សេងៗទៀត។

## កម្ចីអាជីវកម្មខ្នាតតូច

ប្រសិនបើលោកអ្នកជាម្ចាស់អាជីវកម្ម ហើយត្រូវការថវិកាបន្ថែមដើម្បីពង្រីកអាជីវកម្ម ទិញសម្ភារៈបរិក្ខារ ឬបង្កើនទុនបង្វិល ដូច្នេះ ហេតុអ្វីលោកអ្នកមិនដាក់ពាក្យស្នើសុំកម្ចីអាជីវកម្មខ្នាតតូចរបស់ធនាគារ ABA? លោកអ្នកអាចខ្ចីបានរហូតដល់ 200,000.00 ដុល្លារអាមេរិក ជាមួយអត្រាការប្រាក់ទាបសម្រាប់រយៈពេលរហូតដល់ 10ឆ្នាំ។

## កម្ចីតាម ABA Mobile

ប្រសិនបើលោកអ្នកត្រូវការប្រាក់បន្ទាន់ សូមចូលទៅកម្មវិធី ABA Mobile ហើយប្រើ កម្ចីប្រាក់បៀវត្ស ចំពោះអតិថិជនដែលមានគណនីបើកប្រាក់ខែ ABA ឬប្រើ កម្ចីភ្លាមៗតាមរយៈបញ្ញើកាលកំណត់ សម្រាប់អតិថិជនដែលមានគណនីបញ្ញើកាលកំណត់ស្រាប់។ កម្ចីទាំងពីរផ្តល់ជូនលក្ខខណ្ឌងាយៗ ដោយមិនអស់សោហ៊ុយសិក្សាសំណុំលិខិត មិនបំពេញក្រដាសស្នាម ហើយទទួលបានការអនុម័តកម្ចីភ្លាមៗ។

## កម្ចីអាជីវកម្មខ្នាតមធ្យម

ឥណទានអាជីវកម្មខ្នាតមធ្យម ABA ផ្តល់ជូនអតិថិជន នូវលក្ខខណ្ឌងាយស្រួល ការប្រាក់ទាប កញ្ចប់ឥណទានបត់បែន ជាមួយលក្ខខណ្ឌទូទាត់ច្រើនជម្រើស និងភាគរយខ្ពស់នៃអនុបាតឥណទានធៀបនឹងទ្រព្យតម្កល់ ដើម្បីគាំទ្រការពង្រីកអាជីវកម្ម បន្ថែមអាជីវកម្មចម្រុះមុខ និងបង្កើនចំណូលរបស់លោកអ្នក។ យើងខ្ញុំ មានផ្តល់ផលិតផលឥណទាន និងការគាំទ្រជាច្រើន ដើម្បីទ្រទ្រង់ការវិនិយោគ តម្រូវការដើមទុនបង្វិល ការពង្រីកអាជីវកម្ម តម្រូវការប្រតិបត្តិការ និងហិរញ្ញប្បទានពាណិជ្ជកម្ម។

## កម្ចីអាជីវកម្មខ្នាតធំ

ឥណទានអាជីវកម្មខ្នាតធំ ABA គឺជាដំណោះស្រាយហិរញ្ញប្បទានបត់បែន សម្រាប់ផែនការដ៏មោះមុតរបស់លោកអ្នក។ ការយល់ដឹងរបស់យើងខ្ញុំចំពោះតម្រូវការដោយឡែកសម្រាប់អាជីវកម្មរបស់លោកអ្នក គឺពឹងផ្អែកលើបទពិសោធទូលំទូលាយ ពីចម្រុះវិស័យ ចាប់តាំងពី អាជីវកម្មគ្រួសារខ្នាតធំ ដល់សាជីវកម្ម ក្រុមហ៊ុនពហុផលិតផលជាតិ និងអន្តរជាតិ និងក្រុមហ៊ុនពហុជាតិ។ ផលិតផលឥណទានឈានមុខរបស់យើងខ្ញុំ រួមមាន ហិរញ្ញប្បទានទ្រព្យសកម្ម ហិរញ្ញប្បទានដើមទុនបង្វិល (វិនិយោគ) ហិរញ្ញប្បទានពាណិជ្ជកម្មអន្តរជាតិ និងឥណទានផ្សេងៗជាច្រើនទៀត។

# ABA Mobile

ABA Mobile ត្រូវបានបង្កើតឡើងសម្រាប់អតិថិជនមានតម្រូវការសេវាធនាគារលើសពីម៉ោងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារ ហើយអាចប្រើគណនីរបស់ខ្លួនបានគ្រប់ពេល។ ABA Mobile មានមុខងារជាច្រើនសម្រួលដល់ប្រតិបត្តិការសំខាន់ៗប្រចាំថ្ងៃ ដូចជា ការពិនិត្យសមតុល្យក្នុងគណនី, ផ្ទេរប្រាក់ទៅឲ្យអ្នកណាម្នាក់, បង់វិក្កយបត្រ, បើកកាតប្លាស្ទិក, បើកគណនីតាមទូរស័ព្ទ និងមុខងារមានប្រយោជន៍ផ្សេងៗជាច្រើនទៀត។ កម្មវិធីនេះ មានសុវត្ថិភាពខ្ពស់ងាយស្រួលប្រើប្រាស់ ហើយដោនឡូតប្រើដោយឥតគិតថ្លៃ។

សម្រាប់អតិថិជនដែលមិនទាន់មានគណនីធនាគារ មុខងារគណនីរហ័សក្នុង ABA Mobile អនុញ្ញាតឲ្យអ្នកអាចប្រើសេវាធនាគារឌីជីថលដ៏ទំនើប ដោយបើកគណនី ABA ដំបូងត្រឹមតែប៉ុន្មាននាទីប៉ុណ្ណោះ ពីគ្រប់ទីកន្លែង។

## កម្មវិធី ABA Mobile

**ផ្ទេរប្រាក់ទៅអ្នកណាម្នាក់** រួមមាន ធនាគារក្នុងស្រុក, បាគង, វីង, ទ្រូម៉ាន់នី និងដៃគូផ្សេងៗទៀត។

**ផ្ញើប្រាក់ទៅក្រៅប្រទេស** តាមរយៈ SWIFT, សេវាផ្ទេរប្រាក់ Ria, MoneyGram ឬប្រព័ន្ធផ្ទេរប្រាក់រហ័សផ្សេងទៀត គ្រប់ពេលវេលា។

**ទូទាត់វិក្កយបត្រផ្សេងៗ** រួមមាន ថ្លៃទឹកភ្លើង និងសំរាម បង់រំលស់កម្ចីគេហដ្ឋាន និងបញ្ចូលលុយទូរស័ព្ទជាដើម។

**បើកកាតប្លាស្ទិក ឬកាតនិម្មិត** ភ្លាមៗសម្រាប់ការទិញអីវ៉ាន់តាមហាង ឬអនឡាញយ៉ាងងាយស្រួល និងសុវត្ថិភាព។

**បើកគណនីសន្សំ** និងបញ្ញើកាលកំណត់ជាប្រាក់ដុល្លារ និងប្រាក់រៀលដោយផ្ទាល់ក្នុងកម្មវិធី។

**ដកប្រាក់ដោយមិនប្រើកាត** ដោយផ្ញើប្រាក់ទៅនរណាម្នាក់ រួមទាំងផ្ញើទៅអ្នកដែលមិនមានគណនីធនាគារ។

**ទទួលបានការជូនដំណឹងជានិច្ច** និងសារជូនដំណឹងភ្លាមៗ បន្ទាប់ពីប្រតិបត្តិការនីមួយៗបានធ្វើឡើង។

**ទូទាត់បែបឌីជីថល** ដោយស្កេនកូដ KHQR នៅតាមហាង ភោជនីយដ្ឋាន ឬអនឡាញ

## គិតគូរពីសុវត្ថិភាពរបស់អ្នក

ជាមួយ ABA Mobile អ្នកត្រូវបានការពារគ្រប់ពេលចូលប្រើកម្មវិធី ដោយផ្ទៀងផ្ទាត់លេខសម្ងាត់ (PIN) និងចាក់សោពីកម្មវិធីដោយស្វ័យប្រវត្តិពេលបើកចោលដោយមិនប្រើ។ លើសពីនេះ កម្មវិធី ABA Mobile បំពាក់ដោយមុខងារផ្ទៀងផ្ទាត់ជីវមាត្រស្កេនខ្មៅដៃ និងស្កេនផ្ទៃមុខដែលមានសុវត្ថិភាពខ្ពស់។ *

** មុខងារប្រើខ្មៅដៃដើម្បីចូលកម្មវិធីមាននៅលើទូរស័ព្ទឆ្លាតវៃ Android/iOS ដែលមានមុខងារស្កេនខ្មៅដៃ។*
*មុខងារស្កេនផ្ទៃមុខមាននៅលើទូរស័ព្ទ iPhone X ឡើងទៅ។*

# សេវាកាតទូទាត់

## កាតឥណពន្ធ

កាត Visa, Mastercard, UnionPay និង CSS ពីធនាគារ ABA អាចប្រើដើម្បីដកប្រាក់ពីម៉ាស៊ីន ATM ទាំងក្នុង និងក្រៅប្រទេស និងសម្រាប់ទិញអីវ៉ាន់ និងសេវាកម្មផ្សេងៗប្រចាំថ្ងៃផងដែរ។ កាតអន្តរជាតិយើងខ្ញុំ ត្រូវបានបំពាក់ដោយបច្ចេកវិទ្យា NFC ដូច្នេះ លោកអ្នកអាចបង់ប្រាក់ដោយគ្រាន់តែយកកាតប៉ះម៉ាស៊ីនទូទាត់តាមហាងរាប់ពាន់ ដែលមានមុខងារទូទាត់ចរន្តជិត។ កាតរបស់យើងខ្ញុំ ក៏អាចប្រើប្រាស់បានលើ PayPal សម្រាប់ការទូទាត់នៅហាងអនឡាញធំៗល្បីៗផងដែរ។ គ្រប់កាតឥណពន្ធយើងខ្ញុំទាំងអស់ អាចស្នើបើក និងគ្រប់គ្រងចាត់ចែងដោយផ្ទាល់ក្នុង ABA Mobile។ បន្ទាប់ពីបើកកាតរួច លោកអ្នកអាចកំណត់កម្រិតប្រតិបត្តិការ និងកម្រិតដកប្រាក់ ឬបង្កើនកម្រិតអតិបរមាកាតជាបណ្ដោះអាសន្ននៅក្នុងកម្មវិធី។ ABA Mobile ក៏អនុញ្ញាតឲ្យអ្នកភ្ជាប់កាតច្រើនទៅកាន់គណនីតែមួយ ឬប្ដូរគណនីភ្ជាប់កាតបានយ៉ាងងាយស្រួល។

ដើម្បីសុវត្ថិភាព លោកអ្នកអាចប្ដូរលេខសម្ងាត់ (PIN) កាតតាមកម្មវិធី ហើយក្នុងករណីចាំបាច់ លោកអ្នកអាចបិទកាតនោះតែម្ដងក៏បាន។

លើសពីនេះ លោកអ្នកអាចបើក **កាតនិម្មិត** នៅក្នុង ABA Mobile និងប្រើសម្រាប់ទិញអីវ៉ាន់នៅតាមហាងអនឡាញដែលទទួលទូទាត់តាមកាត Mastercard , Visa ឬ UnionPay។

## កាតឥណទាន

ធនាគារ ABA ចេញកាតឥណទាន Mastercard និង VISA ដែលទទួលស្គាល់ទូទាំងពិភពលោក។ កាតឥណទាន អនុញ្ញាតឲ្យអ្នកប្រើប្រាក់របស់ធនាគារនៅពេលត្រូវការបន្ទាន់។ អតិថិជនដែលបានបើកគណនីចរន្ត ឬ គណនីសន្សំ, គណនីកាលកំណត់ ABA ជាមួយនឹងសមតុល្យបើកអប្បបរមា 3,000ដុល្លារអាមេរិក នឹងមានសិទ្ធិទទួលបានកាតឥណទានដោយឥតគិតថ្លៃដែលអាចប្រើប្រាស់ឥណទានរហូតដល់ទៅ 90% នៃទឹកប្រាក់បង្កកទុក (លក្ខខណ្ឌនានាត្រូវអនុវត្ត)។

## ម៉ាស៊ីនទូទាត់ POS

ម៉ាស៊ីនទូទាត់ POS របស់ធនាគារ ABA អាចធ្វើឲ្យប្រតិបត្តិការអាជីវកម្មកាន់តែងាយស្រួល។ ម៉ាស៊ីនទូទាត់ POS អនុញ្ញាតឲ្យទីតាំងលក់រាយទទួលទូទាត់តាមកាត/ទូទាត់តាមបច្ចេកវិទ្យាចរន្តជិត និងកូដ QR បន្ទាប់ពីម៉ាស៊ីនពិនិត្យឃើញថាកាតមានទឹកប្រាក់អាចទូទាត់បាន។ វាជាមធ្យោបាយដ៏សាមញ្ញមួយដែលជួយបង្កើនភាពប្រកួតប្រជែង និងបង្កើនការលក់ដូរ។ អត្ថប្រយោជន៍ពិសេសមួយទៀត គឺថ្លៃប្រតិបត្តិការទូទាត់ទាប ដោយសារថ្លៃទូទាត់នោះនឹងត្រូវផ្ទេរចូលក្នុងគណនីរបស់ក្រុមហ៊ុនដោយផ្ទាល់តែម្ដង។

## ទិញអីវ៉ាន់ដោយទំនុកចិត្ត

កាត ABA Mastercard, VISA, និង UnionPay ត្រូវបានការពារដោយប្រព័ន្ធសុវត្ថិភាព 3D Secure។ 3D Secure ត្រូវបានបង្កើតឡើងដើម្បីទប់ស្កាត់កុំឲ្យមានការលួចចាយដោយគ្មានការអនុញ្ញាតពីម្ចាស់កាត។ ជាមួយនឹងបច្ចេកវិទ្យានេះ ការទិញអីវ៉ាន់អនឡាញ កាន់តែមានសុវត្ថិភាព ទាំងសម្រាប់អ្នកលក់ និងអ្នកទិញ។ គ្រប់កាតទាំងអស់របស់ ABA សុទ្ធតែមាន 3D Secure សម្រាប់ការប្រើប្រាស់ទិញអីវ៉ាន់អនឡាញ។ សូមប្រាកដថាហាងអនឡាញដែលអ្នកទិញអីវ៉ាន់មានសុវត្ថិភាព និងត្រូវបានការពារដោយប្រព័ន្ធសុវត្ថិភាព "Mastercard Secure Code", "Verified by VISA" ឬ "UnionPay Online Payment"។

## សេវាផ្ទេរភ្លាមៗពីកាតទៅកាត

ធនាគារ ABA សហការជាមួយ Visa, Mastercard និង UnionPay International (UPI) ដើម្បីផ្ដល់ជូននូវសេវាផ្ទេរប្រាក់រហ័ស សុវត្ថិភាព ពីកាតទៅកាត ដោយផ្ទាល់ក្នុង ABA Mobile។ ទាញយកអត្ថប្រយោជន៍នៃបទពិសោធងាយស្រួល គ្មានការរំខានគ្រប់ពេល ជាមួយសេវាផ្ទេរភ្លាមៗពីកាតទៅកាត ដែលអ្នកពេញចិត្តដូចជា សេវាផ្ទេរប្រាក់ Visa Direct Mastercard Send ឬ UnionPay MoneyExpress។

ធនាគារ ABA ផ្តល់ជូនសេវាកម្មផ្ទេរប្រាក់ដ៏សម្បូរបែបសម្រាប់បំពេញតម្រូវការរូបវន្តបុគ្គល និងអាជីវកម្ម។ បណ្តាញធនាគារអន្តរការី និងភាពជាដៃគូជាមួយប្រព័ន្ធសេវាផ្ទេរប្រាក់រហ័សដ៏ធំនៅទូទាំងពិភពលោក បង្កជាលក្ខណៈងាយស្រួលក្នុងការផ្ញើ និងទទួលសាច់ប្រាក់ដោយផ្ទាល់ទៅក្នុងគណនី ABA របស់លោកអ្នកប្រកបដោយសុវត្ថិភាព និងឆាប់រហ័សបំផុត។

ឥឡូវនេះ សេវាផ្ទេរប្រាក់ភាគច្រើនមាននៅក្នុងកម្មវិធី ABA Mobile ដែលអតិថិជនអាចផ្ញើប្រាក់ផ្ទាល់ពីទូរស័ព្ទរបស់ពួកគេ ដោយមិនបាច់អញ្ជើញមកកាន់សាខាធនាគារឡើយ។

# សេវាផ្ទេរប្រាក់

## សេវាផ្ទេរប្រាក់រហ័សអន្តរជាតិ

នៅធនាគារ ABA យើងខ្ញុំក៏មានផ្តល់ជូននូវសេវាផ្ទេរប្រាក់រហ័សឆ្លងប្រទេស ដូចជាសេវាផ្ទេរប្រាក់ Ria និង MoneyGram ដែលមាននៅក្នុងកម្មវិធី ABA Mobile និងនៅតាមសាខានានារបស់ធនាគារ ABA។

ដោយមានបណ្តាញភ្នាក់ងារផ្ទេរប្រាក់ដ៏ទូលំទូលាយចំនួន 447,000 កន្លែង នៅជុំវិញពិភពលោក សេវាផ្ទេរប្រាក់ **MoneyGram** ផ្តល់នូវមធ្យោបាយសុវត្ថិភាពមួយក្នុងការផ្ញើ និងទទួលប្រាក់នៅទូទាំងពិភពលោកដោយមិនគិតថ្លៃសេវាពីអ្នកទទួលឡើយ។ **Ria** ជាសេវាផ្ទេរប្រាក់រហ័ស មាននៅតាមសាខាធនាគារ ABA ដែលមិនគិតថ្លៃសេវាពីអ្នកទទួលផងដែរ។ Ria មានបណ្តាញអន្តរជាតិជាង 507,000 កន្លែងទូទាំងពិភពលោក។

## សេវាផ្ទេរប្រាក់ SWIFT

សេវាផ្ទេរប្រាក់រហ័សទៅ/មកក្រៅប្រទេសសម្រាប់រូបវន្តបុគ្គល ឬក្រុមហ៊ុនសាជីវកម្មតាមរយៈបណ្តាញធនាគារអន្តរការីរបស់ ABA។ ជាមួយនឹងការផ្ទេរប្រាក់ទូរគមនាគមន៍ ដែលមាននៅក្នុងកម្មវិធី ABA Mobile ផ្លែតហ្វម ABA Business និងតាមសាខា ទឹកប្រាក់របស់លោកអ្នក នឹងផ្ទេរចូលក្នុងគណនីអ្នកទទួលយ៉ាងឆាប់រហ័ស និងសុវត្ថិភាព។លេខកូដ SWIFT ធនាគារ ABA៖ ABAAKHPP។

## សេវាផ្ទេរប្រាក់ RemitEx

RemitEx ជាសេវាផ្ទេរប្រាក់សម្រាប់ប្រទេសមួយចំនួនជាមួយនឹងអត្រាប្តូរប្រាក់ថេរដែលអាចប្រើប្រាស់បាននៅពេលរូបិយប័ណ្ណផ្ញើខុសពីរូបិយប័ណ្ណទទួល ដោយធានាថាអ្នកទទួលអាចបើកប្រាក់បាន ដោយមិនមានការប្រែប្រួលតាមអត្រាប្តូរប្រាក់។ សូមសាកសួរព័ត៌មានបន្ថែមពីបុគ្គលិកយើងខ្ញុំ។

## សេវាផ្ទេរប្រាក់ក្នុងស្រុក

មូលដ្ឋាននៃការផ្ទេរប្រាក់រវាងធនាគារ ABA និងធនាគារដទៃទៀតតាម បាគង ប្រព័ន្ធទូទាត់រហ័ស និងផ្ទេរប្រាក់រហ័សផ្សេងៗទៀត។ ប្រតិបត្តិការផ្ទេរប្រាក់ក្នុងស្រុករបស់អ្នកមានភាពងាយស្រួល និងលឿនរហ័ស។

ធនាគារ ABA ផ្តល់ជូនអ្នកនូវដំណោះស្រាយស្ពាន និងជម្រើសផ្តល់ហិរញ្ញប្បទានដែលបានកែសម្រួល ដើម្បីកាត់បន្ថយជាអតិបរមា ឬលុបបំបាត់ហានិភ័យរបស់អ្នក ពាក់ព័ន្ធនឹងប្រតិបត្តិការពាណិជ្ជកម្មទាំងនៅក្នុងប្រទេសកម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀតនៅទូទាំងពិភពលោក។

សេវាកម្មរបស់យើង រួមមាន លិខិតឥណទាន, ការធានារបស់ធនាគារ, លិខិតឥណទានប្រចាំការ, ការប្រមូលឯកសារ, ការប្រឹក្សា, ការចរចា, ការប្រមូលឯកសារក្រោយពេលផ្តល់ហិរញ្ញប្បទាន និងអប្បហារ, កម្ចីហិរញ្ញប្បទានពាណិជ្ជកម្ម, ការសន្យាចំណាយ និងលិខិតូបករណ៍ហិរញ្ញប្បទានពាណិជ្ជកម្មជាច្រើនទៀត។

ក្រុមជំនាញការវិជ្ជាជីវៈ ដែលមានបទពិសោធផ្នែកហិរញ្ញប្បទានពាណិជ្ជកម្ម និងប្រតិបត្តិការឯកសារ នឹងជួយអ្នកនៅគ្រប់ដំណាក់កាលទាំងអស់នៃសកម្មភាពនាំចេញនាំចូលរបស់អ្នក ចាប់តាំងពីពេលចរចាកិច្ចសន្យារហូតដល់ពេលទទួលប្រាក់។

ដោយមានការគាំទ្រពីធនាគារជាតិកាណាដាដែលជាភាគហ៊ុនិករបស់យើង យើងខ្ញុំមានលទ្ធភាពផ្តល់នូវសេវាហិរញ្ញប្បទានពាណិជ្ជកម្មទំនើប និងសុវត្ថិភាពខ្ពស់ដល់អតិថិជន។

## ហិរញ្ញប្បទានពាណិជ្ជកម្ម

### លិខិតឥណទាន

លិខិតឥណទាន គឺជាការធានាជាលាយលក្ខណ៍អក្សរដោយធនាគារមួយដើម្បីធ្វើការទូទាត់សម្រាប់អ្នកលក់ ប្រសិនបើអ្នកលក់បានបំពេញតាមលក្ខខណ្ឌនៃលិខិតឥណទានហើយនោះ។ នេះគឺជាវិធីសាស្ត្រដ៏មានសុវត្ថិភាព និងប្រើប្រាស់ទូទៅជាងគេបំផុតនៅក្នុងពិភពហិរញ្ញប្បទានពាណិជ្ជកម្មអន្តរជាតិ។ លិខិតឥណទានរបស់ធនាគារ ABA អនុវត្តតាមវិធាន UCP600 របស់សភាពាណិជ្ជកម្មអន្តរជាតិ (ICC) និងធានានូវសុវត្ថិភាព និងភាពងាយស្រួលចំពោះប្រតិបត្តិការពាណិជ្ជកម្មនាំចេញ នាំចូលរបស់លោកអ្នក។

### លិខិតធានារបស់ធនាគារ

លិខិតធានារបស់ធនាគារ គឺជាការធានាដែលមិនអាចកែប្រែបានរបស់ធនាគារដែលចេញលិខិត (អ្នកធានា) ដើម្បីធ្វើការទូទាត់ជូនអ្នកទទួលការធានា (អ្នកទទួលផល) ប្រសិនបើកាតព្វកិច្ចជាក់លាក់របស់អ្នកដាក់ពាក្យសុំមិនត្រូវបានបំពេញ ឬបំពេញបានដោយផ្នែក។

ឧទាហរណ៍៖ អ្នកនឹងលក់ផលិតផល ប៉ុន្តែមិនប្រាកដអំពីភាពគួរទទួលឥណទានរបស់អ្នកទិញ មានន័យថាអ្នកអាចមានហានិភ័យពីការមិនបានទទួលការទូទាត់។ លិខិតធានាត្រូវបានរៀបចំឡើងដើម្បីកាត់បន្ថយជាអតិបរមានូវហានិភ័យទាំងនេះ ព្រមទាំងហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការទិញលក់ផងដែរ។

### ការប្រមូលប្រាក់ក្រោយទទួលឯកសារ

ការប្រមូលប្រាក់ក្រោយទទួលឯកសារ គឺជាចរន្តឯកសារ (ហិរញ្ញវត្ថុ និង/ឬពាណិជ្ជកម្ម) រវាងធនាគារ និងធនាគារដោយស្របតាមការរៀបចំជាមុនរវាងអ្នកទិញ និងអ្នកលក់។ ការប្រមូលប្រាក់ក្រោយទទួលឯកសារ ត្រូវបានប្រើប្រាស់នៅពេលអ្នកលក់មិនចង់ដឹកជញ្ជូនទំនិញដោយប្រើប្រាស់វិធីគណនីចំហ ប៉ុន្តែស្របពេលជាមួយគ្នានោះមិនអាចធានាហានិភ័យនៃលិខិតឥណទាន ឬលិខិតូបករណ៍ផ្សេងទៀតឡើយ។

បើប្រៀបធៀបជាមួយនឹងគណនីចំហ ការប្រមូលនេះគឺជាវិធីមានសុវត្ថិភាពជាងសម្រាប់អ្នកលក់។

### កម្ចីហិរញ្ញប្បទានពាណិជ្ជកម្ម

កម្ចីហិរញ្ញប្បទានពាណិជ្ជកម្ម ជាហិរញ្ញប្បទានដើមទុនបង្វិលរយៈពេលខ្លីសម្រាប់អ្នកនាំចូល និងអ្នកនាំចេញ ដើម្បីគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការប្តេជ្ញាចិត្តពាណិជ្ជកម្មរបស់ពួកគេ ទៅលើមូលដ្ឋានប្រតិបត្តិការជាមួយឯកសារពាណិជ្ជកម្មសមស្រប។

កម្ចីហិរញ្ញប្បទានពាណិជ្ជកម្ម អាចត្រូវបានអតិថិជន ABA ប្រើប្រាស់ដើម្បីគាំទ្រពាណិជ្ជកម្មទាំងក្នុងប្រទេស និងអន្តរជាតិសម្រាប់មុនពេលដឹកជញ្ជូន ឬក្រោយពេលដឹកជញ្ជូន ដោយផ្អែកលើដំណាក់កាលផ្សេងៗនៃប្រតិបត្តិការពាណិជ្ជកម្ម។

# បណ្តាញស្វ័យសេវា

## កម្មវិធី ABA Mobile

ABA Mobile ជាកម្មវិធីធនាគារតាមទូរស័ព្ទពេញលេញដំបូងគេនៅកម្ពុជា។ កម្មវិធីនេះជាឧបករណ៍ហិរញ្ញវត្ថុដ៏ល្អមួយសម្រាប់អតិថិជនដែលមានតម្រូវការសេវាធនាគារលើសពីម៉ោងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារដោយអាចប្រើគណនីរបស់ខ្លួនបានគ្រប់ពេល។ អ្នកអាចពិនិត្យសមតុល្យសាច់ប្រាក់, ផ្ទេរប្រាក់ទៅកាន់នរណាម្នាក់, បង់វិក្កយបត្រ ឥតគិតថ្លៃសេវា, បើកកាតនិម្មិត, បើកគណនីបញ្ញើ/សន្សំ, ទូទាត់បែបឌីជីថលដោយស្កែនកូដ QR នៅតាមហាងនានា ឬតាមអនឡាញ និងមុខងារដ៏មានអត្ថប្រយោជន៍ផ្សេងៗទៀតដោយឥតគិតថ្លៃ។ កម្មវិធីនេះមានសុវត្ថិភាព និងងាយស្រួលប្រើ ថែមទាំងអាចដោនឡូតពី Google Play Store Apple App Store និង Huawei App Gallery ដោយឥតគិតថ្លៃ។

គណនីរហ័សនៅក្នុង ABA Mobile ត្រូវបានបង្កើតឡើង សម្រាប់ប្រជាពលរដ្ឋកម្ពុជាពេញវ័យ ដែលចង់ចាប់ផ្តើមប្រើសេវាធនាគារឌីជីថលទំនើប ដោយពួកគាត់អាចបើកគណនី ABA ដំបូង របស់ខ្លួនតាមរយៈកម្មវិធីនេះ ពីគ្រប់ទីកន្លែងដោយប្រើពេលតែពីរបីនាទីប៉ុណ្ណោះ។ គណនីរហ័ស ជំនួសទម្លាប់ចាស់ក្នុងការបើកគណនីធនាគារនៅតាមសាខា ដែលជាធម្មតាតម្រូវឲ្យអ្នកធ្វើដំណើរ និងឆ្លងកាត់នីតិវិធីផ្លូវការដ៏វែងឆ្ងាយនានា។

## ម៉ាស៊ីនស្វ័យសេវា

ធនាគារ ABA មានបណ្តាញម៉ាស៊ីន ATM និងម៉ាស៊ីនស្វ័យសេវា (ម៉ាស៊ីនដក-ដាក់ប្រាក់, ម៉ាស៊ីនដាក់ប្រាក់, ម៉ាស៊ីនដាក់មូលប្បទានបត្រ និងម៉ាស៊ីនបើកកាត) 967ទីតាំង នៅទូទាំងប្រទេស ហើយចំនួននេះបន្តកើនឡើងជាលំដាប់។ ជាមួយម៉ាស៊ីន ATM យើងខ្ញុំ អ្នកអាចដកប្រាក់ ពិនិត្យសមតុល្យគណនី និងដំណើរការកាត ABA ថ្មីរបស់អ្នកយ៉ាងងាយស្រួល។ ជាមួយម៉ាស៊ីនបើកកាត អ្នកអាចបើកកាតថ្មីបានភ្លាមៗនៅទីតាំងផ្ទាល់។ ម៉ាស៊ីនស្វ័យសេវាយើងខ្ញុំអនុញ្ញាតឲ្យអ្នកដាក់ប្រាក់ ឬមូលប្បទានបត្រធនាគារគ្រប់ពេលវេលា ប្រកបដោយសុវត្ថិភាព។ ប្រតិបត្តិការទាំងអស់គឺធ្វើឡើងដោយឥតគិតថ្លៃសម្រាប់ម្ចាស់កាត ABA ឬម្ចាស់គណនីABA។

## ABA 24/7

ABA 24/7 ជាបណ្តាញទីតាំងស្វ័យសេវាដែលផ្តល់ជូនអតិថិជននូវការចូលប្រើគណនីគ្រប់ពេលវេលា និងគ្មានការរំខានសម្រាប់ប្រតិបត្តិការដកប្រាក់ ដាក់ប្រាក់ ដាក់មូលប្បទានបត្រ និងបើកកាតផ្ទាល់នៅទីតាំង ដោយមិនចាំបាច់អញ្ជើញមកសាខាធនាគារ។ ដោយត្រូវបានដាក់ទីតាំងជាយុទ្ធសាស្ត្រ នៅតំបន់ដែលមានចរាចរណ៍មមាញឹក ទីតាំង ABA 24/7 នីមួយៗបំពាក់ដោយម៉ាស៊ីន ATM, ម៉ាស៊ីនដក-ដាក់ប្រាក់ (CRM), ម៉ាស៊ីនដាក់ប្រាក់ (CIM), ម៉ាស៊ីនដាក់មូលប្បទានបត្រ (CDM) និងម៉ាស៊ីនបើកកាត(CM)។

## កម្មវិធី ABA Merchant

ABA Merchant ជាផ្នែកនៃផ្លែតហ្វមទូទាត់អនឡាញ ABA PayWay ដែលអនុញ្ញាតឲ្យអាជីវកម្មនានាទទួលទូទាត់ភ្លាមៗជាមួយស្មាតហ្វូនរបស់គេដោយបង្កើតកូដ QR ឬលីងទូទាត់។ ជាកម្មវិធីដ៏ល្អឥតខ្ចោះសម្រាប់អាជីវកម្ម ដូចជាហាងកាហ្វេ ហាងសម្លៀកបំពាក់ ហាងកែសម្ផស្ស អ្នកលក់តាមបណ្តាញសង្គម អ្នកផ្គត់ផ្គង់សេវាកម្ម និងអាជីវកម្មផ្សេងៗដើម្បីប្រមូលប្រាក់ទូទាត់បែបឌីជីថល ដោយមិនតម្រូវឲ្យមានការភ្ជាប់ប្រព័ន្ធណាមួយបន្ថែមឡើយ។ កម្មវិធីនេះ ជួយដោះស្រាយការងារប្រចាំថ្ងៃរបស់ពាណិជ្ជករ ពាក់ព័ន្ធនឹងការរក្សាទុកកំណត់ត្រាការលក់ព្រមទាំងជួយកាត់បន្ថយការប៉ះពាល់ផ្ទាល់នឹងសាច់ប្រាក់ផងដែរ។

## ផ្លែតហ្វម ABA Business

ផ្លែតហ្វមសេវាធនាគារ ABA Business ផ្តល់មធ្យោបាយដ៏ងាយស្រួល និងសុវត្ថិភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុក្រុមហ៊ុន តាមរយៈការគ្រប់គ្រងរំហូរសាច់ប្រាក់ប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពផ្ទាល់ពីកុំព្យូទ័រ។ សេវាកម្មនេះ ឆ្លើយតបគ្រប់តម្រូវការសេវាធនាគារសម្រាប់អាជីវកម្ម ដូចជាការអនុញ្ញាតប្រតិបត្តិការ និងការទូទាត់ដល់ក្រុមហ៊ុនផ្គត់ផ្គង់ ឬបុគ្គលិក, ពិនិត្យសមតុល្យគណនី និងពិនិត្យប្រតិបត្តិការថ្មីៗ, ផ្ទេរប្រាក់ក្នុង និងក្រៅប្រទេស, ប្រព័ន្ធប្រតិបត្តិការផ្ទាល់ (Host-to-Host), គណនីនិម្មិត និងមុខងារជាច្រើនទៀត។

## បណ្ដាញទំនាក់ទំនងអតិថិជន 24/7

### មជ្ឈមណ្ឌលទំនាក់ទំនងអតិថិជន

លោកអ្នកអាចលើកឡើងនូវសំណួរ ការមិនពេញចិត្ត និងសំណើរបស់លោកអ្នកដែលពាក់ព័ន្ធនឹងផលិតផលនិងសេវាកម្មរបស់ធនាគារ ABA ដោយទូរស័ព្ទមកកាន់អ្នកឯកទេសខាងបម្រើអតិថិជនរបស់ធនាគារយើងខ្ញុំ។ ប្រសិនបើកាតរបស់លោកអ្នកត្រូវបានបាត់ ឬត្រូវគេលួច ឬចង់ដឹងម៉ោងធ្វើការ និងទីតាំងសាខាដែលនៅជិតលោកអ្នកបំផុត ឬមានចម្ងល់ពាក់ព័ន្ធនឹងការប្រើប្រាស់មុខងារណាមួយ នៅលើអេប ABA Mobile សូមទាក់ទងមកទូរស័ព្ទលេខ 1 800 203 203 (ប្រព័ន្ធទូរស័ព្ទឥតគិតថ្លៃសម្រាប់ការហៅចេញក្នុងប្រទេសកម្ពុជា) ឬ +855(0)98 203 333 ដើម្បីឲ្យបុគ្គលិកធនាគារ ABA បម្រើជូន។

### ទំព័រ Facebook

នៅលើទំព័រ Facebook ផ្លូវការរបស់យើងខ្ញុំ លោកអ្នកតែងតែទទួលបាននូវព័ត៌មានថ្មីចុងក្រោយបំផុតពីផលិតផល និងសេវាកម្មរបស់ធនាគារ ABA ក៏ដូចជាអាចទស្សនាវីដេអូសាជីវកម្មអំពីធនាគារ, ឆាតឆ្លើយឆ្លងមកកាន់ក្រុមការងារ, ទទួលបានព័ត៌មានអំពីប្រូម៉ូសិនថ្មីៗ និងអាចចូលរួមលេងហ្គេមឆ្លើយសំណួរយករង្វាន់ផ្សេងៗពីយើងខ្ញុំផងដែរ។ សូមចូលទៅកាន់ទំព័រយើងខ្ញុំ www.facebook.com/ABA.Bank.Cambodia ។

### ការបញ្ចេញមតិ ABA Mobile

រីករាយជាមួយសេវាធនាគារងាយស្រួល និងសុវត្ថិភាពពីកម្មវិធី ABA Mobile ហើយអ្នកអាចទាក់ទងមកយើងខ្ញុំបានភ្លាមៗដោយមិនចាំបាច់បិទកម្មវិធី។ គ្រាន់តែចូលទៅអេក្រង់ដើមរបស់កម្មវិធី ហើយចុចប៊ូតុង "**ទាក់ទងមកយើងខ្ញុំ**"។ នៅទីនោះ លោកអ្នកអាចសរសេរជាមតិយោបល់ ឬសួរសំណួរអំពីផលិតផល ឬសេវាកម្មរបស់ធនាគារ, ជជែកជាមួយយើងខ្ញុំតាម Facebook Messenger ឬទូរស័ព្ទមកកាន់លេខប្រចាំការ 24ម៉ោងរបស់យើងខ្ញុំ ដោយមិនចាំបាច់ចុចលេខអ្វីទាំងអស់។

### ការឆ្លើយឆ្លងតាមគេហទំព័រ

ការឆ្លើយឆ្លងតាមគេហទំព័រ www.ababank.com.kh អាចឲ្យលោកអ្នកទាក់ទងតាមអនឡាញមកកាន់ក្រុមការងារយើងខ្ញុំ ដើម្បីទទួលបានព័ត៌មានអំពីផលិតផល និងសេវាកម្មមួយចំនួនបានដោយមិនចាំបាច់ទូរស័ព្ទមកកាន់យើងខ្ញុំ ឬធ្វើដំណើរមកកាន់សាខាណាមួយឡើយ។ ក្រុមការងារនៅរង់ចាំស្វាគមន៍ឆ្លើយតបរាល់សំណើរបស់អតិថិជនគ្រប់ពេលវេលា និង 365ថ្ងៃក្នុងមួយឆ្នាំ។

### ការបញ្ចេញមតិតាមអ៊ីមែល

នៅ ABA យើងខ្ញុំស្វាគមន៍ជានិច្ចរាល់មតិយោបល់របស់លោកអ្នក។ ប្រសិនបើលោកអ្នកចង់ឲ្យយើងខ្ញុំបម្រើជូនតាមសំណើណាមួយ ឬផ្ដល់យោបល់ដើម្បីកែលម្អបុគ្គលិករបស់យើងខ្ញុំ សូមផ្ញើអ៊ីមែលមកកាន់ info@ababank.com។



## គណនីរហ័ស



ធនាគារ ABA បង្កើតមុខងារគណនីរហ័សនៅក្នុងកម្មវិធី ABA Mobile សម្រាប់អ្នកដែលមិនទាន់មានគណនី ABA។ ជាមួយវត្តមានគណនីរហ័ស អ្នកមិនចាំបាច់អញ្ជើញទៅធនាគារ មិនពិបាករង់ចាំតាមលេខរៀង ឬបំពេញឯកសារអ្វីឡើយ។ ប្រជាពលរដ្ឋកម្ពុជាមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានសុពលភាព អាចបើកគណនី ABA ដំបូងរបស់ខ្លួនបានតាមកម្មវិធី ABA Mobile ដោយប្រើពេលតែពីរបីនាទី ហើយចាប់ផ្តើមប្រើប្រាស់សេវាធនាគារឌីជីថលទំនើបថ្មីទាំងស្រុង!

ជាមួយគណនីរហ័ស អ្នកអាចពិនិត្យសមតុល្យគណនីរបស់អ្នកបានភ្លាមៗ, បើកគណនីបញ្ញើ/សន្សំ, ស្នើសុំកម្ចីភ្លាមៗ, ស្នើសុំកាតប្លាស្ទិក ឬបើកកាតនិម្មិត, ទទួល និងផ្ទេរប្រាក់នៅក្នុងប្រទេសកម្ពុជា, ទូទាត់វិក្កយបត្រ និងបញ្ចូលលុយទូរស័ព្ទ, ធ្វើការដកប្រាក់មិនប្រើកាតនៅតាមម៉ាស៊ីន ATM, ទូទាត់បែបឌីជីថលជាមួយ ABA PAY និងទទួលបានសារជូនដំណឹងសម្រាប់រាល់ប្រតិបត្តិការនីមួយៗ។

គណនីរហ័ស អាចដាក់ប្រាក់ចូលបានយ៉ាងងាយស្រួលតាមម៉ាស៊ីនដាក់ប្រាក់(CIM) និងម៉ាស៊ីនដក-ដាក់ប្រាក់(CRM) របស់ធនាគារ ABA តាមរយៈការទទួលប្រាក់ផ្ទេរពីអ្នកប្រើ ABA ដូចគ្នា ឬពីកាបូបអេឡិកត្រូនិក (e-wallets) ដែលជាដៃគូធនាគារ ABA ដូចជា បាគង ទ្រូម៉ាន់នី និងវីងជាដើម។

## ផ្លែតហ្វម ABA PayWay

ABA PayWay គឺជាផ្លែតហ្វមទូទាត់អនឡាញ ដែលបង្កើតឡើងសម្រាប់ពាណិជ្ជកម្មអេឡិកត្រូនិក និងអាជីវកម្មតាមបណ្តាញសង្គមនៅកម្ពុជា។

ផ្លែតហ្វមនេះអាចប្រើបានតាមរយៈកម្មវិធី ABA Merchant និងផតថល PayWay លើវិបសាយ payway.com.kh។

ABA Merchant ជាផ្លែតហ្វមដ៏ល្អឥតខ្ចោះ សម្រាប់អាជីវកម្មខ្នាតតូច ព្រោះកម្មវិធីនេះ ជួយឲ្យអាជីវកម្ម ទទួលប្រាក់ទូទាត់បែបឌីជីថល ឬអនឡាញ ដោយបង្កើតកូដ QR ឬលីងទូទាត់ផ្ទាល់លើស្មាតហ្វូន។ កម្មវិធីនេះ សម្រួលដល់ការងារប្រចាំថ្ងៃក្នុងការរក្សាកំណត់ត្រាការលក់ និងការទទួលប្រាក់ទូទាត់។

សម្រាប់អាជីវកម្ម ដែលតម្រូវឲ្យមានការគ្រប់គ្រងប្រតិបត្តិការច្រើន និងប្រើមុខងារបន្ថែម ផតថលពាណិជ្ជករ PayWay សក្តិសមបំផុត ក្នុងការផ្តល់លក្ខខណ្ឌល្អប្រសើរ សម្រាប់ការភ្ជាប់ប្រព័ន្ធ។ ផតថលនេះ ផ្តល់នូវការបត់បែនកាន់តែច្រើន ក៏ដូចជាទិន្នន័យលើប្រតិបត្តិការអាជីវកម្មរបស់អ្នកផងដែរ។

យើងបានបង្កើតផ្លែតហ្វមទូទាត់អនឡាញ ABA PayWay ដោយផ្តោតលើភាពងាយស្រួលរបស់លោកអ្នក ដើម្បីផ្តល់លក្ខខណ្ឌដ៏ប្រសើរបំផុត សម្រាប់ភ្ជាប់កម្មវិធីនេះជាមួយអាជីវកម្មរបស់លោកអ្នក។

## ABA Business

ផ្លែតហ្វមសេវាធនាគារ ABA Business ផ្តល់ជូននូវមធ្យោបាយដ៏ងាយស្រួល និងមានសុវត្ថិភាពសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុក្រុមហ៊ុន ដែលលោកអ្នកអាចប្រើប្រាស់ដើម្បីគ្រប់គ្រងរំហូរសាច់ប្រាក់ប្រកបដោយប្រសិទ្ធភាព និងភាពងាយស្រួលផ្ទាល់ពីកុំព្យូទ័រ។

ជាមួយ ABA Business អ្នកអាចគ្រប់គ្រងគណនី ឬបើកគណនីបញ្ញើសម្រាប់អាជីវកម្ម ខណៈដែលអាចតាមដានរាល់គណនីរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រោមគណនីមេតែមួយ, ផ្ទេរប្រាក់ទៅមករវាងគណនីខ្លួនឯង និងគណនីធនាគារផ្សេង ទាំងក្នុងនិងក្រៅប្រទេស, បង់វិក្កយបត្រ និងថ្លៃទូទាត់ដល់ក្រុមហ៊ុនផ្គត់ផ្គង់ ដោយបង្កើតគំរូទូទាត់ប្រតិបត្តិការដែលធ្វើឡើងញឹកញាប់។ ប្រសិនបើលោកអ្នកជាអតិថិជនកម្ចីយើងខ្ញុំ លោកអ្នកអាចបង់កម្ចីសម្រាប់អាជីវកម្មបានយ៉ាងងាយស្រួល និងទទួលសាររំលឹកសម្រាប់ការបង់នៅខែបន្ទាប់។

យើងក៏ផ្តល់ជូននូវសេវាបើកបៀវត្ស ដែលលោកអ្នកអាចបើកប្រាក់ខែជូនបុគ្គលិកបានយ៉ាងងាយស្រួល និងមានសុវត្ថិភាព ដែលអាចកាត់បន្ថយថ្លៃចំណាយ លុបបំបាត់ការងារលើសន្លឹកក្រដាស និងបង្កើនសុវត្ថិភាព។ ជាផ្នែកមួយនៃសេវាបើកបៀវត្សយើងខ្ញុំក៏មានបើកកាតឥណពន្ធជូនបុគ្គលិកលោកអ្នកក្នុងអត្រាពិសេស ដើម្បីប្រើប្រាស់ក្នុងការដកប្រាក់តាមបណ្តាញ ATM របស់យើងខ្ញុំ ក៏ដូចជាទិញអីវ៉ាន់ និងទូទាត់អនឡាញ។

# ធនាគារអន្តរការី

ធនាគារ ABA បានរៀបចំជាតារាងធនាគារអន្តរការី ជាមួយធនាគារអន្តរជាតិល្បីៗនៅជុំវិញពិភពលោក។ ប្រតិបត្តិការអាជីវកម្ម ពាណិជ្ជកម្មទាក់ទងនឹងការបង់ប្រាក់ និងសេវាផ្ទេរប្រាក់លក្ខណៈផ្ទាល់ខ្លួនត្រូវបានធ្វើឡើងតាមរយៈគណនីទាំងនេះតាមរូបិយប័ណ្ណរបស់ពួកគេ។

ខាងក្រោមនេះជាតារាងធនាគារអន្តរការីរបស់យើង ដែលអាចជ្រើសរើសបានដើម្បីជួយសម្រួលដល់ការទូទាត់លក្ខណៈអន្តរជាតិ។



| រូបិយប័ណ្ណ | ឈ្មោះធនាគារអន្តរការី | លេខកូដ SWIFT |
|---|---|---|
| USD | JPMorgan Chase Bank National Association, សហរដ្ឋអាមេរិក | CHASUS33 |
| USD | Standard Chartered Bank, សហរដ្ឋអាមេរិក | SCBLUS33 |
| USD | Standard Chartered Bank Limited, ប្រទេសសិង្ហបុរី | SCBLSG22 |
| USD | Woori Bank, ប្រទេសកូរ៉េខាងត្បូង | HVBKKRSE |
| USD | Kookmin Bank, ប្រទេសកូរ៉េខាងត្បូង | CZNBKRSE |
| USD | KEB Hana Bank, ប្រទេសកូរ៉េខាងត្បូង | KOEXKRSE |
| USD | DBS Bank, ប្រទេសសិង្ហបុរី | DBSSSGSG |
| USD | Oversea-Chinese Banking Corporation, ប្រទេសសិង្ហបុរី | OCBCSGSG |
| USD | Joint Stock Commercial Bank for Foreign Trade of Vietnam, ប្រទេសវៀតណាម | BFTVVNVX |
| VND | Joint Stock Commercial Bank for Foreign Trade of Vietnam, ប្រទេសវៀតណាម | BFTVVNVX |
| CAD | National Bank of Canada, ប្រទេសកាណាដា | BNDCCAMMINT |
| USD | National Bank of Canada, ប្រទេសកាណាដា | BNDCCAMMINT |
| EUR | National Bank of Canada, ប្រទេសកាណាដា | BNDCCAMMINT |
| EUR | Commerzbank AG, ប្រទេសអាល្លឺម៉ង់ | COBADEFF |
| GBP | Standard Chartered Bank, ប្រទេសអង់គ្លេស | SCBLGB2L |
| SGD | DBS Bank, ប្រទេសសិង្ហបុរី | DBSSSGSG |
| CNY | China Construction Bank Corporation, ប្រទេសចិន | PCBCCNBJGPS |
| THB | Standard Chartered Bank (Thai), ប្រទេសថៃ | SCBLTHBX |
| THB | Kasikornbank Public Company Limited, ប្រទេសថៃ | KASITHBK |
| KRW | Woori Bank, ប្រទេសកូរ៉េខាងត្បូង | HVBKKRSE |
| AUD | JPMorgan Chase Bank National Association, ប្រទេសអូស្ត្រាលី | CHASAU2X |
| JPY | Sumitomo Mitsui Banking Corporation, ប្រទេសជប៉ុន | SMBCJPJT |

# បណ្តាញសាខា

**ការិយាល័យកណ្តាល**

អគារលេខ 141, 146, 148, 148 អា បេ សេ ដេ និង 162អា មហាវិថីព្រះសីហនុ និង អគារលេខ 15 និង153 អា បេ សេ
ផ្លូវលេខ 278 និង អគាលេខ 171 ផ្លូវត្រសក់ផ្អែម សង្កាត់បឹងកេងកង 1 ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ប្រព័ន្ធឥតគិតថ្លៃ៖ 1 800 203 203
លេខកូដ SWIFT៖ **ABAAKHPP**

អ៊ីមែល៖ Info@ababank.com
វិបសាយ៖ www.ababank.com

| | |
|---|---|
| សាខាស្រុកកណ្តាលស្ទឹង | 098 203 619 |
| សាខាខេត្តកែប | 081 205 707 |
| សាខាខេត្តក្រចេះ | 098 203 049 |
| សាខាខេត្តកោះកុង | 081 204 123 |
| សាខាស្រុកកោះធំ | 081 204 186 |
| សេវាអតិថិជនការិយាល័យកណ្តាល | 098 203 179 |
| សាខាស្រុកកៀនស្វាយ | 098 203 479 |
| សាខាខេត្តកំពង់ចាម | 098 203 879 |
| សាខាខេត្តកំពង់ឆ្នាំង | 098 203 039 |
| សាខាខេត្តកំពង់ធំ | 098 203 429 |
| សាខាខេត្តកំពង់ស្ពឺ | 098 203 949 |
| សាខាស្រុកកំពង់ត្រឡាច | 081 204 149 |
| សាខាស្រុកកំពង់ត្រាចកើត | 098 206 535 |
| សាខាខេត្តកំពត | 098 203 959 |
| សាខាច្បារអំពៅ | 098 203 929 |
| សាខាចោមចៅ | 098 203 939 |
| សាខាចោមចៅ 2 | 081 204 420 |
| សាខាចោមចៅ 3 | 081 205 721 |
| សាខាចំការដូង | 098 203 579 |
| សាខាស្រុកចំការលើ | 081 204 053 |
| សាខាជ្រោយចង្វារ | 098 203 189 |
| សាខាស្រុកជើងព្រៃ | 098 203 749 |
| សាខាស្រុកឈូក | 098 203 729 |

| | |
|---|---|
| សាខាខេត្តតាកែវ | 098 203 909 |
| សាខាក្រុងតាខ្មៅ | 098 203 919 |
| សាខាខេត្តត្បូងឃ្មុំ | 098 203 769 |
| សាខាស្រុកត្រាំកក់ | 098 203 709 |
| សាខាស្រុកថ្មគោល | 098 203 789 |
| សាខាទឹកថ្លា | 098 203 849 |
| សាខាទួលគោក | 098 203 859 |
| សាខាទួលគោក 2 | 098 203 637 |
| សាខាខេត្តបន្ទាយមានជ័យ | 098 203 759 |
| សាខាបឹងត្របែក | 098 206 750 |
| សាខាបុរីកីឡា | 098 203 869 |
| សាខាខេត្តប៉ៃលិន | 081 204 659 |
| សាខាស្រុកបាកាន | 081 204 209 |
| សាខាខេត្តបាត់ដំបង | 098 203 839 |
| សាខាក្រុងបាត់ដំបង | 098206548 |
| សាខាស្រុកបាទី | 098 203 649 |
| សាខាស្រុកបាទី២ | 098 206 941 |
| សាខាក្រុងបាវិត | 098 203 389 |
| សាខាស្រុកបារាយណ៍ | 098 203 739 |
| សាខាក្រុងប៉ោយប៉ែត | 098 203 019 |
| សាខាផ្សារថ្មី | 098 203 979 |
| សាខាផ្សារដើមថ្កូវ | 098 203 689 |
| សាខាស្រុកពារាំង | 081 204 292 |

| | |
|---|---|
| សាខាស្រុកពួក | 081 207 200 |
| សាខាស្រុកពាមរក៍ | 098 203 629 |
| សាខាស្រុកព្រៃឈរ | 081 204 189 |
| សាខាខេត្តព្រៃវែង | 098 203 059 |
| សាខាខេត្តព្រៃនប់ | 081 204 297 |
| សាខាខេត្តពោធិ៍សាត់ | 098 203 969 |
| សាខាខេត្តព្រះសីហនុ | 098 203 899 |
| សាខាស្រុកព្រះនេត្រព្រះ | 081 204 262 |
| សាខាខេត្តព្រះវិហារ | 081 204 590 |
| សាខាស្រុកមង្គលបូរី | 081 204 029 |
| សាខាមិត្តភាព | 081 204 307 |
| សាខាស្រុកមុខកំពូល | 098 203 159 |
| សាខាខេត្តមណ្ឌលគិរី | 081 204 567 |
| សាខាស្រុកមេមត់ | 098 203 639 |
| សាខាស្រុកមោងឫស្សី | 098 203 459 |
| សាខាម៉ៅសេទុង | 023 203 809 |
| សាខាខេត្តរតនគិរី | 098 203 499 |
| សាខាខេត្តស្ទឹងត្រែង | 081 204 090 |
| សាខាវិមានឯករាជ្យ | 098 203 001 |
| សាខាសម្តេចសុធារស | 098 203 983 |
| សាខាសម្តេចមុនីរ៉េត | 081 204 019 |
| សាខាសង់ត្រាល់ | 098 203 199 |
| សាខាសន្ធរម៉ុក | 098 203 469 |

| | |
|---|---|
| សាខាសែនសុខ | 098 203 779 |
| សាខាស្ពានចាស់ | 098 203 819 |
| សាខាស្ទឹងមានជ័យ | 098 203 889 |
| សាខាស្ទឹងមានជ័យ២ | 098 206 180 |
| សាខាស្រុកសូទ្រនិគម | 081 204 283 |
| សាខាក្រុងសៀមរាប-ផ្សារលើ | 098 203 679 |
| សាខាក្រុងសៀមរាប-អង្គរ | 098 203 089 |
| សាខាខេត្តសៀមរាប | 098 203 829 |
| សាខាស្រុកស្អាង | 098 203 099 |
| សាខាស្រុកសំរោងទង | 098 203 719 |
| សាខាសំរោងក្រោម | 081 205 735 |
| សាខាស្រុកស្ទោង | 081 204 355 |
| សាខាស្រុកស្វាយជ្រំ | 098 203 349 |
| សាខាខេត្តស្វាយរៀង | 098 203 029 |
| សាខាស្រុកស្អាង | 098 203 369 |
| សាខាស្រុកអង្គស្នួល | 098 203 489 |
| សាខាស្រុកអង្គរជ័យ | 098 206 776 |
| សាខាអូរបែកក្អម | 098 203 799 |
| សាខាអ៊ីអនម៉ល (សែនសុខ) | 098 203 149 |
| សាខាអ៊ីអនម៉ល (មានជ័យ) | 081 205 720 |
| សាខាស្រុកឧដុង្គ | 098 203 379 |
| សាខាខេត្តឧត្តរមានជ័យ | 081 204 693 |
| សាខាឫស្សីកែវ | 098 203 659 |

ABA BANK
NATIONAL BANK OF CANADA GROUP

អគារលេខ 141, 146, 148, 148 អា បេ សេ ដេ និង 162អា មហាវិថីព្រះសីហនុ
និង អគារលេខ 15 និង153 អា បេ សេ ផ្លូវលេខ 278 និង អគាលេខ 171 ផ្លូវត្រសក់ផ្អែម
សង្កាត់បឹងកេងកង 1 ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ប្រព័ន្ធឥតគិតថ្លៃ៖ 1 800 203 203 | www.ababank.com | លេខកូដ SWIFT៖ **ABAAKHPP**